សូមមើលវីដេអូ ភាគទី ១

# សិក្សាព្រះអភិធម្ម

# បរមត្ថធម៌

ពាក្យថា **បរមត្ថ** មកពី **បរម** + **អត្ថ** = **បរមត្ថ**

**បរម** ប្រែថា ប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត

**អត្ថ** ប្រែថា អត្ថ, សេចក្តី ឬន័យ

រួមពាក្យទាំងពីរចូលគ្នា បានជា **បរមត្ថ** ប្រែថា អត្ថ ឬសេចក្តីដ៏ប្រសើរ។

# បរមត្ថធម៌ មាន ៤ គឺ ÷

| | |
|---|---|
| ១-ចិត្តបរមត្ថ | បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង |
| ២-ចេតសិកបរមត្ថ | បានដល់ ចេតសិក ៥២ |
| ៣-រូបបរមត្ថ | បានដល់ រូប ២៨ |
| ៤-និព្វានបរមត្ថ | បានដល់ ព្រះនិព្វាន |

# រូបបរមត្ថ
# បរិច្ឆេទទី ៦

## រូបបរមត្ថ (MATTER)

រូប មានវចនត្ថៈថា រុប្បតីតិ = រូបំ ឈ្មោះថា រូប ព្រោះអត្ថថា ប្រែកប្លាយ គឺ រមែងប្រែកប្លាយ ដោយបច្ច័យដែលជាសត្រូវមាន ត្រជាក់ និងក្ដៅជាដើម ។

# លក្ខណាទិចតុក្កៈរបស់រូប

១ - រុប្បនលក្ខណំ	រូបមានការបែកធ្លាយ ជាលក្ខណៈ

២ - វិកិរណរសំ	មានការខ្ចាត់ខ្ចាយ (ឬមានការមិនដឹងអារម្មណ៍) ជាកិច្ច

៣ - អព្យាកតបច្ចុប្បដ្ឋានំ	មានភាពជាអព្យាកត ជាអាការប្រាកដ

៤ - វិញ្ញាណបទដ្ឋានំ	មានវិញ្ញាណ ជាបទដ្ឋាន ។

រូបមាន ២៨ គឺ ៖ មហាភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១

រួមជានិប្ផន្នរូប ១៨ ។

បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ និងលក្ខណរូប ៤

រួមជាអនិប្ផន្នរូប ១០ ។

រូបទាំង ២៨ ចែកជាប្រភេទធំៗមាន ២ គឺ មហាភូតរូប ៤ និង ឧបាទាយរូប ២៤ តែបើចែកដោយប្រភេទតូចៗ មានរូប ១១ ពួកដូចតទៅនេះ គឺ ៖

| | | |
|---|---|---|
| ១ - មហាភូតរូប ៤ | បានដល់ | **បឋវី អាបោ តេជោ វាយោ** |
| ២ - បសាទរូប ៥ | បានដល់ | **ចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ កាយបសាទ** |
| ៣ - វិសយរូប ៤ | បានដល់ | **វណ្ណៈ សទ្ទៈ គន្ធៈ រសៈ** |
| ៤ - ភាវរូប ២ | បានដល់ | **ឥត្ថីភាវៈ បុរិសភាវៈ** |
| ៥ - ហទយរូប ១ | បានដល់ | **ហទយវត្ថុ** |

| | | |
|---|---|---|
| ៦ - ជីវិតរូប ១ | បានដល់ | ជីវិតិន្ទ្រិយ |
| ៧ - អាហាររូប ១ | បានដល់ | កពឡិង្ការាហារ |
| ៨ - បរិច្ឆេទរូប ១ | បានដល់ | អាកាសធាតុ |
| ៩ - វិញ្ញត្តិរូប ២ | បានដល់ | កាយវិញ្ញត្តិ វចីវិញ្ញត្តិ |
| ១០ - វិការរូប ៣ | បានដល់ | លហុតា មុទុតា កម្មញ្ញតា |
| ១១ - លក្ខណរូប ៤ | បានដល់ | ឧបចយៈ សន្តតិ ជរតា អនិច្ចតា ។ |

បណ្តារូប ២៨ នេះ ក្នុងបាលីចែកទុកជា ២ ពួក គឺ

សភាវរូប ១ និង អសភាវរូប ១ ។

**សភាវរូប** បានដល់ មហាភូតរូប ៤ ប្រសាទរូប ៥

វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១

អាហាររូប ១ ។

រូប ១៨ នេះ មានឈ្មោះហៅបាន ៥ យ៉ាង គឺ ៖

| | |
|---|---|
| ១ - **សភាវរូប** | រូបដែលមានភាវៈរបស់ខ្លួន |
| ២ - **សលក្ខណរូប** | រូបដែលមានលក្ខណៈ |
| ៣ - **និប្ផន្នរូប** | រូបដែលកើតអំពីសមុដ្ឋាន ៤ |
| ៤ - **រូបរូប** | រូបដែលបែកធ្លាយ |
| ៥ - **សម្មសនរូប** | រូបដែលគួរពិចារណា |

## ១ - បឋវីធាតុ (The earth-element)

បឋវីធាតុ មានលក្ខណៈ ២ គឺ ៖

១ - កក្ខឡ បឋវី  បឋវីដែលមានភាពរឹង ជាលក្ខណៈ (Hardness)

២ - អថទ្ធ បឋវី  បឋវីដែលមានភាពមិនរឹង ជាលក្ខណៈ (Softness)

បឋវី មានវចនត្ថៈថា ៖ **បត្ថីនត្ថេន = បឋវី** ឈ្មោះថា **បឋវី**

ព្រោះអត្ថថា **រឹង** ។

ន័យមួយទៀត **សហជាតរូបានិ បឋន្តិ បតិដ្ឋហន្តិ ឯត្ថាតិ = បឋវី**

ប្រែថាសហជាតរូបទាំងឡាយ រមែងអាស្រ័យ តាំងនៅក្នុងធាតុនេះ

ព្រោះហេតុនោះធាតុនេះ ទើបឈ្មោះថា **បឋវី** ។




## លក្ខណាទិចតុក្កៈរបស់បឋវី

១ - **កក្ខឡត្តលក្ខណា** មានភាពរឹង ជាលក្ខណៈ

២ - **បតិដ្ឋានរសា** មានការតាំងមាំ ជាកិច្ច

៣ - **សម្បដិច្ឆន្នបច្ចុប្បដ្ឋានា** មានភាពជាទីទទួលរង ជាអាការប្រាកដ

៤ - **អវសេសធាតុត្តយបទដ្ឋានា** មានធាតុ ៣ ដែលនៅសល់ ជាហេតុជិត ។

# បឋវីធាតុមាន ៤ យ៉ាង ៖

១ - **បរមត្ថបឋវី** ឬ **លក្ខណបឋវី** បានដល់ ធាតុដីដែលមានភាពរឹង ឬទន់ជាសភាវៈ

២ - **សសម្ភារបឋវី** ឬ **សុត្តន្តបឋវី** បានដល់ធាតុដីដែលមានចំណែកប្រកប មានទាំងខាងក្នុងកាយ និងខាងក្រៅកាយ ។

រូបក្នុងកាយរបស់សត្វ ជាឧបាទិន្នរូប ហៅថា **អជ្ឈត្តិកបវរី** ។

រូបខាងក្រៅកាយរបស់សត្វ ជាអនុបាទិន្នរូប ហៅថា **ពាហិរបវរី** ។

អជ្ឈត្តិកបវរី មាន ២០ ចែកជា ៤ ពួកគឺ ៖

| ពួកតចបញ្ចកៈ | | ពួកវក្កបញ្ចកៈ | |
|---|---|---|---|
| ១ - កេសា | សក់ | ៦ - មំសំ | សាច់ |
| ២ - លោមា | រោម | ៧ - នហារូ | សរសៃ |
| ៣ - នខា | ក្រចក | ៨ - អដ្ឋិ | ឆ្អឹង |
| ៤ - ទន្តា | ធ្មេញ | ៩ - អដ្ឋិមិញ្ជំ | ខួរក្នុងឆ្អឹង |
| ៥ - តចោ | ស្បែក | ១០ - វក្កំ | តម្រងបស្សាវៈ |

## ពួកបច្ឆាសបញ្ចកៈ

១១ - ហទយំ បេះដូង

១២ - យកនំ ថ្លើម

១៣ - កិលោមកំ វាវ

១៤ - បិហកំ ក្រពះ

១៥ - បប្ផាសំ សួត

## ពួកមត្ថលុង្គបញ្ចកៈ

១៦ - អន្តំ ពោះវៀនធំ

១៧ - អន្តគុណំ ពោះវៀនតូច

១៨ - ឧទរិយំ អាហារថ្មី

១៩ - ករីសំ អាហារចាស់

២០ - មត្ថលុង្គំ ខួរក្នុងក្បាល

**ពាហិរបឋវី** គឺ ធាតុដីខាងក្រៅ បានដល់ ធម្មជាតិដែលរឹង ជាអនុបាទិន្នរូបដូចជា **អយោ** ដែក; **លោហំ** លោហៈ; **តិបុ** សំណប៉ាហាំង; **សីសំ** សំណភក់; **សង្ឃ** ប្រាក់; **មុត្តា** កែវមុក្តា; **មណិ** កែវមណី ជាដើម ។

៣ - **កសិណបឋវី** ឬ **អារម្មណបឋវី** បានដល់ បឋវីកសិណ ឬដី ដែលជា អារម្មណ៍របស់សមថកម្មដ្ឋាន ។

៤ - **សម្មុតិបឋវី** ឬ **បកតិបឋវី** បានដល់ ធាតុដីដែលសន្មត ហៅថា ដី ដុំដី ទីដី ផ្ទៃដី ផែនដី ។

សូមមើលវីដេអូ ភាគទី ២

# ២ - អាបោធាតុ (The element of cohesion)

**អាបេតិ សហជាតរូបានិ បត្ថរតិ អប្បាយតិ វា ព្រូហេតិ វឌ្ឍេតីតិ** = **អាបោ** ដែលឈ្មោះថា **អាបោ** ដោយអត្ថថា ជ្រួតជ្រាប គឺ ផ្សើមទៅកាន់រូបដែលកើតរួមគ្នា ឬ ឈ្មោះថា **អាបោ** ដោយអត្ថថា ធ្វើឲ្យសហជាតរូបជិតស្និទ្ធ កពូន ឬចម្រើន ដុះដាល ធាត់ធំ ។

ម្យ៉ាងទៀត **សហជាតរូបានិ អវិប្បកិណ្ណានិ កត្វា ភុសោ បាតិ រក្ខតីតិ** = **អាបោ** ធាតុណា រមែងឃុំគ្រងរក្សា យ៉ាងក្រៃលែងនូវសហជាតរូបទាំងឡាយមិនឲ្យខ្ចាត់ខ្ចាយ ព្រោះហេតុនោះ ធាតុនោះឈ្មោះថា **អាបោ** ។

**បរមត្ថអាបោ** មានលក្ខណៈ ២ គឺ ៖

**១ - បគ្ឃរណអាបា** ធាតុទឹកដែលមានលក្ខណៈហូរជ្រាប ។ វត្ថុណា មានអាបោធាតុច្រើនជាងបឋវីធាតុភាពរឹងកាន់តែតិច និងធ្វើឲ្យបឋវីធាតុដែលកើតរួមគ្នានោះហូរទៅ ដូចទឹកក្នុងទន្លេ ស្ទឹងជាដើម ។

**២ - អាពន្ទនអាបោ** ធាតុទឹកដែលមានលក្ខណៈជាប់ស្អិត ។ វត្ថុណាមានអាបោធាតុតិចជាងបឋវីធាតុ ក៏ធ្វើ ឲ្យវត្ថុនោះជាប់ស្អិតគ្នាជាដុំ គឺធ្វើឲ្យបរមាណូនៃបឋវីធាតុ ក្លាយជាដុំជាប់គ្នា ជារូបរាងសណ្ឋានផ្សេងៗ ដូចជាផែនដី ភ្នំ ដើមត្នោត ទំពាំង ភ្លុកដំរីជាដើម ។

ម្យ៉ាងទៀត អាបោធាតុ ដែលត្រូវតេជោធាតុដុតរោលឲ្យក្ដៅ រហូតដល់អាចហូរទៅបាន ដូចជាដែក មាស ប្រាក់ និង ក្រមួនឃ្មុំជាដើម ប្រព្រឹត្តទៅដោយអំណាចនៃតេជោធាតុធ្វើឲ្យហូរ អាបោធាតុដែលមានលក្ខណៈ ជាប់ស្អិតនោះ ព្រោះមានតេជោធាតុផ្សំនៅតិច ។

# លក្ខណាទិចតុក្កៈរបស់អាបោ

| | |
|---|---|
| ១ - បគ្ឃរណលក្ខណា | មានការហូរ សើម ជាលក្ខណៈ |
| អាពន្ធនលក្ខណា វា | ឬ មានការជាប់ស្អិត ជាលក្ខណៈ |
| ២ - ឧបព្យូហនរសា | មានការចូលទៅកពូន ជាកិច្ច |
| ៣ - សង្គហបច្ចុប្បដ្ឋានា | មានការតោងរួមផ្ដុំទុក ជាអាការប្រាកដ |
| ៤ - អវសេសធាតុត្តយបទដ្ឋានា | មានធាតុ ៣ ដែលនៅសល់ ជាហេតុជិត ។ |

## អាបោធាតុមាន ៤ យ៉ាង ៖

១ - **បរមត្ថអាបោ** ឬ **លក្ខណអាបោ** បានដល់ ធាតុទឹកដែលជាបរមត្ថ ដូចបានពណ៌នាខាងលើ

២ - **សសម្ភារអាបោ** ឬ **សុត្តន្តអាបោ** បានដល់ ធាតុទឹកព្រមទាំងគ្រឿងប្រកប ចែកជាពីរចំណែកគឺ ៖

**អជ្ឈត្តិកអាបោ** ធាតុទឹកដែលមាននៅក្នុងកាយរបស់សត្វ ជាឧបាទិន្នករូប មាន ១២ ចែកជាពីរពួកដូច្នេះ ៖

| **ពួកមេទឆក្កៈ** | | **ពួកមុត្តឆក្កៈ** | |
|---|---|---|---|
| **១ - បិត្តំ** | ទឹកប្រមាត់ | **៧ - អស្សុ** | ទឹកភ្នែក |
| **២ - សេម្ហំ** | ស្លេស្ម៍ | **៨ - វសា** | ខ្លាញ់រាវ |
| **៣ - បុព្វោ** | ទឹកខ្ទុះ | **៩ - ខេឡោ** | ទឹកមាត់ |
| **៤ - លោហិតំ** | ឈាម | **១០ - សិង្ឃានិកា** | ទឹកសម្បោរ |
| **៥ - សេទោ** | ញើស | **១១ - លសិកា** | ទឹករំអិល |
| **៦ - មេទោ** | ខ្លាញ់ខាប់ | **១២ - មុត្តំ** | ទឹកមូត្រ ។ |

**ពាហិរអាបោ** បានដល់ ធាតុទឹកខាងក្រៅ ជាអនុបាទិន្នករូប ដូចជា ទឹកឫសឈើ ទឹកដើមឈើ ទឹកសម្បកឈើ ទឹកស្លឹកឈើ ទឹកផ្កា និងទឹកផ្លែឈើជាដើម ។

**៣ - កសិណអាបោ** ឬ **អារម្មណអាបោ** បានដល់ អាបោកសិណ ឬ ទឹកដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន មានទឹកក្នុងបាត្រ ក្នុងអាង និងទឹកក្នុងផ្តិលជាដើម។

**៤ - សម្មុតិអាបោ** ឬ **បកតិអាបោ** បានដល់ ធាតុទឹកដែលសន្មតគ្នាថា ទឹកផឹក និងទឹកងូតជាដើម ។

ជាសាមណេរ

ត្រូវមានគ្រូពីរយ៉ាងសំខាន់

១- ឧបជ្ឈាយ៍ គឺអ្នកបំបួស មានតួនាទីសម្លឹងមើលទោស និងណែនាំអំពីអភិសមាចារជាដើម

២- អាចារ្យ គឺភិក្ខុជាគ្រូបង្រៀន មានវិន័យជាដើម ។

ត្រូវតែតាំងនៅក្នុងការបង្រៀនរបស់លោកទាំងពីរអស់មួយជីវិត។

បើជាភិក្ខុ ត្រូវតាំងក្នុងការបង្រៀនណែនាំក្នុងសណាក់លោកទាំងពីរ ៥ ឆ្នាំ ។


ឧបចយ
ជរតា
អនិច្ចតា
ខណៈបដិសន្ធិ
សន្តតិ
ជរតា
អនិច្ចតា
ក្នុងបវត្តិកាល

# ទុក្ខសាការកម្មដ្ឋាន

## ទុក្ខស + អាការ + កម្មដ្ឋាន

# អង្គអ្នករៀន ៤ យ៉ាង

អ្នករៀនរឿងព្រះត្រៃ	បិដកថ្លៃតាមចំនួន
ប្រកបដោយអង្គបួន	គឺ សុ- ចិ- បុ- លិ- ចាំ ។
សុ- ប្រែថាស្ដាប់គេ	ចិ- គ្មាន់គ្នេរគិតចំណាំ
បុ- ឲ្យសាកសួរសាំ	លិ- ឲ្យចម្លងកត់ត្រា ។
បើអ្នកប្រាសចាកបង់	អំពីអង្គបួនប្រការ
ពុំបានជាអាចារ្យ	រៀនចាស់ស្លាប់ក៏ពុំចេះ ។